# ឯកសារទី ១

សូមអានសាច់រឿងខាងក្រោមឮៗ ៖

មិត្តម្នាក់របស់អ្នកកំពុងរៀនជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ នាងដើរមករកអ្នក ហើយពោលថា « កាលពីមេរៀនលើកមុន ពួកអ្នកផ្សព្វផ្សាយសាសនាបានអញ្ជើញឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំជឿលើព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកអ្វីដែលពួកអ្នកផ្សព្វផ្សាយសាសនាកំពុងបង្រៀនខ្ញុំ ។ ប៉ុន្តែខ្ញុំពុំយល់ថា ហេតុអ្វីបានជាខ្ញុំត្រូវទទួលបុណ្យជ្រមុជទឹក ដោយសារខ្ញុំធ្លាប់ទទួលបុណ្យជ្រមុជទឹករួចហើយនៅក្នុងព្រះវិហាររបស់ខ្ញុំកាលពីក្មេង » ។

សូមពិភាក្សាជាមួយដៃគូរបស់អ្នកពីរបៀបដែលអ្នកនឹងឆ្លើយតបដល់មិត្តម្នាក់នេះដោយប្រើ ម៉ាថាយ ៣:១៣–១៧ ។ សូមរៀបចំខ្លួនចែកចាយអ្វីដែលអ្នកពិភាក្សា ។ ( សូមមើលផងដែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ២២ ដើម្បីរៀនពីរបៀបដែលព្រះអម្ចាស់មានបន្ទូលតបទៅមនុស្សមួយចំនួនដែលបានបង្ហាញកង្វល់ដូចគ្នានេះនៅសម័យដើមនៃការស្ដារឡើងវិញ ) ។

# ឯកសារទី ២

សូមអានសាច់រឿងខាងក្រោមឮៗ ៖

អ្នក និងមិត្តម្នាក់របស់អ្នក ដែលជាអ្នកជឿសាសនាគ្រីស្ទ កំពុងមានការពិភាក្សាមួយអំពីសាសនា ។ គាត់ងាកមករកអ្នកហើយពោលថា « ខ្ញុំជឿថាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គតែមួយ ។ តើឯងជឿខុសពីនេះដែរទេ ? បើមែន ហេតុអ្វីទៅ ? »

សូមពិភាក្សាពីរបៀប ដែលអ្នកនឹងឆ្លើយតបដល់មិត្តម្នាក់នេះដោយប្រើ ម៉ាថាយ ៣:១៣–១៧ ។ សូមរៀបចំខ្លួនចែកចាយអ្វីដែលអ្នកពិភាក្សា ។ ( សូមពិចារណាប្រើដំណើររឿងក្នុង ម៉ាថាយ ៣ព្រមគ្នាជាមួយនឹង យ៉ូហាន ១៧:២០–២២ ។ ខគម្ពីរទាំងនេះកត់ត្រាថា ព្រះយេស៊ូវបានអធិស្ឋានទូលសុំព្រះវរបិតាធ្វើឲ្យពួកអ្នកដើរតាមទ្រង់ទាំងអស់រួបរួមគ្នាតែមួយដូចជាទ្រង់ និងព្រះវរបិតា [ មានព្រះរាជបំណង ] តែមួយ ។ ព្រះយេស៊ូវពុំបានណែនាំថា ពួកសិស្សនៃព្រះគ្រីស្ទនឹងក្លាយជាមនុស្សតែមួយនោះទេ ) ។



© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។